## ទាក់ទងមកពួកយើង

សូមប្រើឧបករណ៍ទំនាក់ទំនងខាងក្រោម ដើម្បីចូលប្រើព័ត៌មានគម្រោងបន្ថែម សួរសំណួរ ឬផ្តល់មតិយោបល់៖


Michael Cano, មន្ត្រីប្រតិបត្តិ
ផែនការ និងការអភិវឌ្ឍទូទាំងខោនធី
Metro
One Gateway Plaza, MS 99-13-1
Los Angeles, CA 90012

213.418.3010

*710corridor@metro.net*

*metro.net/lb-ela-cp-hub*

*@metrolosangeles*

*losangelesmetro*


24-0643 ©2023 LACMTA

metro.net/lb-ela-cp-hub

# យើងកំពុងបង្កើតចក្ខុវិស័យថ្មីសម្រាប់គច្រករបៀងឡុងប៊ិច-ឡូសអេនជឺឡេសភាគខាងកើត

### ផែនការវិនិយោគចល័តច្រករបៀង LONG BEACH-LA ខាងកើត
សន្លឹកព័ត៌មាន



Metro

រដូវក្តៅ 2023

## ទិដ្ឋភាពទូទៅ

Metro មានផែនការសម្រាប់ច្រករបៀង Long Beach-LA ខាងកើត (ច្រករបៀង LB-ELA) ដោយការសហការជាដៃគូជាមួយសមាជិកសហគមន៍សំខាន់ៗ និងភាគីពាក់ព័ន្ធនានាក្នុងតំបន់តាមបណ្តោយច្រករបៀង និងការអភិវឌ្ឍផែនការវិនិយោគមួយដោយប្រើទឹកប្រាក់ប្រមាណ 730 លានដុល្លារនៅក្នុងចំណូលពន្ធលើការលក់ ដែលអាចប្រើប្រាស់រួមជាមួយថវិការបស់រដ្ឋនិងសហព័ន្ធ ដើម្បីបង្កើតគម្រោងនិងកម្មវិធីដឹកជញ្ជូនដែលផ្តល់ជម្រើសពហុមុខងារ ប្រកបដោយគុណភាពមានសុវត្ថិភាព សម្រាប់ចរាចរមនុស្សនិងទំនិញ។ ការកែលម្អទាំងនេះនឹងជំរុញឱ្យមានខ្យល់អាកាសបរិសុទ្ធ (គ្មានការបញ្ចេញផ្សែងពុល) សហគមន៍មានសុខភាពល្អនិងមាននិរន្តរភាព និងការផ្តល់អំណាចសេដ្ឋកិច្ចដល់អ្នកស្រុក សហគមន៍ និងអ្នកប្រើប្រាស់ទាំងអស់ដែលស្ថិតនៅតាមបណ្តោយច្រករបៀងនេះ។

Metro បានបង្កើតក្រុមការងារច្រករបៀង LB-ELA ដើម្បីធ្វើការងារជាមួយសមាជិកសហគមន៍ ដើម្បីធានាបានថាជម្រើសចល័តភាពត្រូវបានរួមបញ្ចូលទៅក្នុងផែនការវិនិយោគ ប្រកបដោយសមធម៌និងនិរន្តរភាពជាអាទិភាព។ ផែនការវិនិយោគនឹងត្រូវបានពង្រាងនិងដាក់ជូនទៅកាន់ក្រុមប្រឹក្សាភិបាល Metro សម្រាប់ការពិចារណានៅក្នុងខែវិច្ឆិកា ឆ្នាំ 2023។

## គោលដៅគម្រោង

> **គុណភាពខ្យល់៖** លើកកម្ពស់គុណភាពខ្យល់អាកាសបរិសុទ្ធតាមមូលដ្ឋាននិងក្នុងតំបន់

> **ចល័តភាព៖** កែលម្អចល័តភាពរបស់ប្រជាជននិងទំនិញ

> **សហគមន៍៖** គាំទ្រដល់សហគមន៍ដែលរីកចម្រើនដោយការលើកកម្ពស់សុខភាព និងគុណភាពជីវិតរស់នៅរបស់អ្នកស្រុក

> **សុវត្ថិភាព៖** អនុញ្ញាតឱ្យមធ្យោបាយធ្វើដំណើរទាំងអស់កាន់តែមានសុវត្ថិភាព

> **បរិស្ថាន៖** លើកកម្ពស់បរិស្ថានធម្មជាតិនិងកែច្នៃ

> **វិបុលភាព៖** ពង្រឹងភាពប្រកួតប្រជែងផ្នែកសេដ្ឋកិច្ចរបស់ខោនធី LA និងបង្កើនការទទួលបានការងារប្រកបដោយគុណភាព ការអភិវឌ្ឍកម្លាំងការងារ និងឱកាសសេដ្ឋកិច្ចសម្រាប់សហគមន៍ទាំងអស់ ដោយផ្តោតទៅលើការពង្រឹងសហគមន៍ច្រករបៀង LB-ELA ដែលបាននិងកំពុងបន្ទរងការប៉ះពាល់ពីសកម្មភាពសេដ្ឋកិច្ចនិងការអភិវឌ្ឍ

> **ឱកាស៖** បង្កើនលទ្ធភាពទទួលបានការងារដែលមានគុណភាពនៅក្នុងសហគមន៍ ការអភិវឌ្ឍកម្លាំងពលកម្ម និងឱកាសសេដ្ឋកិច្ច

## អំពីក្រុមការងារ

Metro បានបើកដំណើរការក្រុមការងារនៅរដូវស្លឹកឈើជ្រុះឆ្នាំ 2021 ដើម្បីឆ្លើយតបទៅនឹងការសម្រេចរបស់ Metro និង Caltrans ក្នុងការផ្អាកគម្រោង I-710 ពីមុន និងឆ្លើយបតទៅនឹងសហគមន៍ដែលបង្ហាញពីតម្រូវការសម្រាប់ចក្ខុវិស័យខុសគ្នាសម្រាប់ការកែលម្អចល័តភាព សុវត្ថិភាព គុណភាពខ្យល់ និងគុណភាពជីវិតទូទៅនៅក្នុងច្រករបៀង។

ក្រុមការងាររួមមានសមាសភាពអង្គការតាមសហគមន៍ ក្រុមតស៊ូមតិបរិស្ថាន អង្គការបម្រើសេវាសហគមន៍ ទីភ្នាក់ងារទីក្រុងនិងរដ្ឋាភិបាល ចរាចរណ៍ទំនិញ ឡូជីស្ទីក ការដឹកជញ្ជូន កម្លាំងពលកម្ម និងក្រុមអាជីវកម្ម។

> គណៈកម្មាធិការដឹកនាំសហគមន៍ (CLC) – រួមមានអ្នកស្រុករហូតដល់ទៅ 29 រូបដែលពួកគេតំណាងឱ្យសហគមន៍នៅតាមច្រករបៀង Long Beach-Los Angeles ខាងកើត

> គណៈកម្មាធិការសម្របសម្រួល – គឺជាគណៈកម្មាធិការដែលមានសមាជិកប្រាំរូប ដែលតំណាងឱ្យក្រុមការងារ និងសមាជិក CLC

> ក្រុមការងារសមធម៌ – រួមមានក្រុមការងារ និងសមាជិក CLC និងផ្តល់ឱវាទស្តីពីរបៀបដែលផែនការវិនិយោគនឹងដោះស្រាយបញ្ហាវិសមភាព និងផ្តល់ជូនអត្ថប្រយោជន៍ដល់មនុស្សគ្រប់គ្នា

> ក្រុមការងាររថយន្តដឹកទំនិញមិនបញ្ចេញផ្សែងពុល –ផ្តល់ឱវាទដល់ Metro លើការបង្កើតកម្មវិធីរថយន្តដឹកទំនិញមិនបញ្ចេញផ្សែងពុល រួមមានតំបន់សម្រាប់លទ្ធភាពសិក្សាស្រាវជ្រាវបន្ថែម ការពិចារណា និងការអភិវឌ្ឍដើម្បីសម្រេចវត្ថុបំណងនៃការធ្វើចរាចរទំនិញមិនបញ្ចេញផ្សែងពុលនៅតាមច្រករបៀង LB-ELA

## កាលវិភាគ

| រដូវស្លឹកឈើជ្រុះឆ្នាំ 2021 – រដូវរងាឆ្នាំ 2022 | រដូវរងា – រដូវស្លឹកឈើជ្រុះឆ្នាំ 2022 | រដូវស្លឹកឈើជ្រុះឆ្នាំ 2022 – រដូវរងាឆ្នាំ 2023 | និទាឃរដូវ – រដូវស្លឹកឈើជ្រុះឆ្នាំ 2023 | រដូវស្លឹកឈើជ្រុះឆ្នាំ 2023 – រដូវរងាឆ្នាំ 2024 | រដូវរងា – និទាឃរដូវឆ្នាំ 2024 |
|---|---|---|---|---|---|
| ភាគីពាក់ព័ន្ធការចូលរួម<br><br>ការកសាងទំនុកចិត្ត និងការកំណត់ការព្រមព្រៀងមតិ | ការកំណត់ចក្ខុវិស័យ គោលដៅ និងការណែនាំគោលការណ៍នានា | ការបង្កើតយុទ្ធសាស្ត្រចម្រុះ និងរកឱ្យឃើញគម្រោងនិងកម្មវិធី | ការវាយតម្លៃ និងកែសម្រួលគម្រោង និងកម្មវិធី | ការបង្កើតការវិនិយោគ និងយុទ្ធសាស្ត្រគោលនយោបាយសម្រាប់ការអនុវត្ត | រាយការណ៍ទៅកាន់ក្រុមប្រឹក្សា Metro |

## ផែនការវិនិយោគចល័តច្រករបៀង LONG BEACH-LA ខាងកើត សិក្សាពីទីតាំងភូមិសាស្ត្រ

